FAMILY RELATIONSHIPS ONLINE
HELPING FAMILIES BUILD BETTER RELATIONSHIPS

An Australian Government Initiative

# ទំនាក់ទំនងគ្រួសារតាមអនឡាញ

**ការជួយគ្រួសារនានាដើម្បីកសាងទំនាក់ទំនងកាន់តែល្អ**

- ការព្រងឹងទំនាក់ទំនងគ្រួសារ
- ការជួយគ្រួសារនានាអោយស្នាក់នៅជាមួយគ្នា
- ការជួយគ្រួសារនានាដែលឆ្លងកាត់ការបែកគ្នា

## តើអ្វីជាទំនាក់ទំនងគ្រួសារតាមអនឡាញ ?

ទំនាក់ទំនងគ្រួសារតាមអនឡាញគឺជាសេវារបស់រដ្ឋាភិបាល អូស្ត្រាលីដែលត្រូវបានរៀបចំដើម្បីផ្តល់ដល់គ្រួសារទាំងអស់ (មិនថារស់នៅជាមួយគ្នា ឬបានបែកគ្នា) ដែលទទួលបានព័ត៌មានងាយស្រួលតាមអនឡាញស្តីពីបញ្ហានានាទាក់ទងនឹងទំនាក់ទំនងគ្រួសារ។

តំបន់បណ្តាញគឺជាប្រភពនៃព័ត៌មានស្តីពីសេវាឧបត្ថម្ភគាំទ្រ នានាសំរាប់ទំនាក់ទំនងគ្រួសារ។

## តើព័ត៌មានអ្វីខ្លះដែលខ្ញុំអាចរកបាននៅលើទំនាក់ទំនងគ្រួសារតាមអនឡាញ ?

លោកកអ្នកអាចរកឃើញស្តីពីសេវានានាដើម្បីជួយលោកអ្នក និងគ្រួសាររបស់លោកអ្នកដើម្បីគ្រប់គ្រងបញ្ហានានានៅក្នុងការធ្វើទំនាក់ទំនង រួមមាន ការយល់ព្រមលើការរៀបចំចាត់ចែងសមស្របនានាសំរាប់កូនៗ ក្រោយពីឪពុកម្តាយបែកគ្នា។ លោកកអ្នកក៏អាចរកបាននូវព័ត៌មានស្តីពីមាតិកានានាដែលមាន តាំងពីការ កសាងទំនាក់ទំនងអោយកាន់តែល្អ រហូតដល់ដំណោះស្រាយទំនាស់គ្រួសារ។

## ទំនាក់ទំនងគ្រួសារតាមអនឡាញ រួមមានព័ត៌មានស្តីពីៈ

- ការកសាងនិងការរក្សាទំនាក់ទំនងអោយមាំខ្លាំង
- ការទាក់ទងប្រកបដោយប្រសិទ្ធិភាពជាមួយសមាជិកទាំងអស់នៃគ្រួសារ
- ការធ្វើការរៀបចំចាត់ចែងសំរាប់កូនៗក្រោយពីការបែកគ្នា
- ធនធាននានាដើម្បីជួយលោកអ្នកនៅពេលមានអំពើហឹង្សាគ្រួសារ
- ដំណោះស្រាយទំនាស់គ្រួសារ
- របៀបដើម្បីទាក់ទងអ្នកផ្តល់ដំណោះស្រាយទំនាស់គ្រួសារដែលបានចុះបញ្ជី
- ការជួយឧបត្ថម្ភកូនៗនិងមនុស្សនៅក្មេងនៅពេលគ្រួសារបែកគ្នា
- សេវាពិគ្រោះយោបល់នៅក្នុងតំបន់របស់លោកអ្នក
- ច្បាប់គ្រួសារ

## តើខ្ញុំរកព័ត៌មាន ឬសេវានានានៅលើទំនាក់ទំនងគ្រួសារតាមអនឡាញយ៉ាងដូចម្តេច?

ការរកព័ត៌មាន ឬសេវានានានៅលើទំនាក់ទំនងគ្រួសារតាមអនឡាញគឺមានភាពងាយស្រួល។ ប្រសិនបើលោកអ្នកដឹងពីមាតិកាណាដែលលោកអ្នកចាប់អារម្មណ៍ នោះលោកអ្នកអាចវាយពាក្យគន្លឹះសំខាន់ទៅក្នុង ប្រអប់រក ឬជ្រើសរើសមាតិកាសមស្របណាមួយ។ តាមរបៀបណាមួយ នោះលោកអ្នកនឹងត្រូវផ្តល់អោយនូវ តំណភ្ជាប់សង្ខេបទៅនឹងក្រដាសអង្គហេតុដែលពាក់ព័ន្ធ ឬ សេវាជាច្រើន។

លោកអ្នកក៏អាចរកនូវសេវាសមស្របនានានៅជិតកន្លែងដែលលោកអ្នករស់នៅ។

## តើខ្ញុំចូលទៅទំនាក់ទំនងគ្រួសារតាមអនឡាញយ៉ាងដូចម្តេច?

នរណាក៏អាចចូលទៅអ៊ីនធ័រណិតអាចប្រើប្រាស់ទំនាក់ទំនងគ្រួសារតាមអនឡាញបានដែរ។ ប្រសិនបើលោកអ្នកមិនមានការភ្ជាប់អ៊ីនធ័រណិតនៅឯផ្ទះ

លោកអ្នកអាចចូលទៅតំបន់បណ្តាញពីបណ្ណាល័យតាមតំបន់របស់លោកអ្នក ពីសាលារៀន ឬពីអ៊ីនធ័រណេិតកាហ្វេ។ ដោយគ្រាន់តែវាយពាក្យជាសាមញ្ញ www.familyrelationships.gov.au ទៅក្នុងកម្មវិធីរុករក បណ្តាញនិងធ្វើតាមតំណភ្ជាប់នានាទៅកាន់ព័ត៌មានស្តីពីសុខាមាលភាពនៃទំនាក់ទំនងគ្រួសារ។

ជាជំនួស លោកអ្នកអាចហៅទូរស័ព្ទទៅខ្សែទូរស័ព្ទផ្តល់ដំបូន្មានទំនាក់ទំនងគ្រួសារតាមលេខ **1800 050 321 ម៉ោង 8 ព្រឹក ដល់ម៉ោង 8 ល្ងាច ពីថ្ងៃ ច័ន្ទ ដល់ថ្ងៃ សុក្រ និងម៉ោង 10 ព្រឹក – 4 ល្ងាច នៅថ្ងៃ សៅរ៍** (លើកលែងតែនៅថ្ងៃឈប់សំរាកជាតិសាធារណៈ)។

សំរាប់ព័ត៌មានបន្ថែមស្តីពីទំនាក់ទំនងគ្រួសារ និងសេវានានា ដែលអាចជួយបាន។

## ទស្សនា

ទំនាក់ទំនងគ្រួសារតាមអនឡាញ នៅឯ www.familyrelationships.gov.au

## ឬ ហៅទូរស័ព្ទ
## ខ្សែទូរស័ព្ទផ្តល់ដំបូន្មានទំនាក់ទំនងគ្រួសារ

**1800 050 321**

ម៉ោង 8 ព្រឹក – 8 ល្ងាច ពីថ្ងៃ ច័ន្ទ ដល់ថ្ងៃ សុក្រ

10 ព្រឹក – 4 ល្ងាច នៅថ្ងៃ សៅរ៍ (ម៉ោងនៅតាមមូលដ្ឋាន)

លើកលែងតែនៅថ្ងៃឈប់សំរាកជាតិសាធារណៈ